

# បច្ចេកវិទ្យាក្រោយប្រមូលផលស្រូវ

*ដោយ*
*គម្រោងបន្ថយការបាត់បង់ក្រោយប្រមូលផល និងបង្កើនចំណូលដោយផលិតស្រូវមានគុណភាពល្អ IRRI-ADB*

ដោយពិនិត្យឃើញថានៅតំបន់អាស៊ីអគ្នេយ៍ការច្រូតកាត់ បោកបែន សម្អាត ហាលសម្ងួត ទុកដាក់និងកិនស្រូវតាមទម្លាប់ តែងធ្វើឲ្យបាត់បង់ជាទម្ងន់ពី១៥ ទៅ ១៧% ហើយការបាត់បង់គុណភាពធ្វើឲ្យបាត់បង់តម្លៃពី ១០ ទៅ ៣០% បន្ថែមទៀត វិទ្យាស្ថានស្រាវជ្រាវដំណាំស្រូវអន្តរជាតិ (IRRI) បានសហការជាមួយស្ថាប័នកសិកម្មជាតិនៅប្រទេសចំនួន ៣ គឺ កម្ពុជា វៀតណាម និង ហ្វីលីពីន ដើម្បីអនុវត្តគម្រោងមួយឈ្មោះ“ ការកាត់បន្ថយការបាត់បង់នៅក្រោយពេលប្រមូលផលនិងការបង្កើនប្រាក់ចំណូល ដោយផលិតស្រូវអង្ករមានគុណភាពខ្ពស់ជាងមុន” ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២ ដោយប្រើប្រាស់ថវិការបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

ក្នុងទិសដៅរួមចំណែកធ្វើឲ្យមានសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ គម្រោងនេះបានលើកឡើងនូវគោលបំណងជាក់លាក់មួយចំនួន ដូចជា : ១) ធ្វើឲ្យសាយភាយនូវបច្ចេកវិទ្យាក្រោយប្រមូលផលដែលបានបញ្ជាក់ផ្ទៀងផ្ទាត់ថាមានប្រសិទ្ធភាព ២) កាត់បន្ថយការបាត់បង់ស្រូវអង្ករនៅក្រោយពេលប្រមូលផល ៣) បង្កើនប្រាក់ចំណូលពីស្រូវអង្កររបស់កសិករ ៤) ពង្រឹងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងឯកជន និង ៥) អភិវឌ្ឍវិស័យក្រោយប្រមូលផលស្រូវឲ្យមាននិរន្តរភាព ។

នៅកម្ពុជា គម្រោងនេះសហការអនុវត្តជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានគ្រឿងយន្តកសិកម្ម នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្មខេត្ត) និងសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ នៅភូមិ៥៦ ក្នុងខេត្ត៦ គឺ បាត់ដំបង ពោធិសាត់ កំពង់ធំ ព្រៃវែង តាកែវ និងកំពត ដោយព្យាយាមធ្វើឲ្យការបាត់បង់ស្រូវអង្ករនៅក្រោយពេលប្រមូលផលចុះទាបជាងមុនយ៉ាងតិច ៥%។

បច្ចេកវិទ្យាទាំងឡាយដែលយកចិត្តទុកដាក់អនុវត្តដើម្បីធ្វើឲ្យកសិករ និងអ្នកពាក់ព័ន្ធចាប់អារម្មណ៍ ហើយទទួលយកទៅអនុវត្តគឺការច្រូតកាត់ ការបោកបែន និងការសម្ងួតដោយម៉ាស៊ីន ការទុកដាក់ក្នុងប្រព័ន្ធបិទជិត ការកិនស្រូវដោយម៉ាស៊ីនមានគុណភាព និងការកៀពង្រាបដីដោយប្រព័ន្ធឡាស៊ែរ។ ជាមួយនោះ ឧបករណ៍ចាំបាច់មួយចំនួនដើម្បីវាស់កំណត់គុណភាពស្រូវអង្ករ ដូចជាឧបករណ៍វាស់សំណើម ភាពប្រេះស្រាំ សីតុណ្ហភាព និងជាតិពុល (ផ្សិត) របស់ស្រូវអង្ករ ព្រមទាំងម៉ាស៊ីនកិនស្រូវប្រភេទមន្ទីរពិសោធន៍ឧបករណ៍វាស់សំណើមធៀបបរិយាកាសជាដើម ក៏ត្រូវបានបញ្ចូលប្រើប្រាស់ដែរ។

**អ្នកទទួលផលពីគម្រោងមានជាអាទិ៍គឺ :**

១. កសិករ : ដើម្បីឲ្យគាត់ ក) បាត់បង់តិចជាងមុន ធ្វើឲ្យគាត់មានស្រូវលក់កាន់តែច្រើន ខ) មានស្រូវអង្ករល្អជាងមុនធ្វើឲ្យគាត់លក់បានថ្លៃ គ) កើនសមត្ថភាពទុកដាក់ធ្វើឲ្យគាត់អាចសម្រេចចិត្តលក់នៅពេលបានថ្លៃ ឃ) បន្ថយការប្រើប្រាស់ថ្នាំពុល ធ្វើឲ្យអាហាររបស់ គាត់គ្មានគ្រោះថ្នាក់ដល់សុខភាព និង ង) យល់ដឹងច្រើនអំពីតម្លៃ និងតម្រូវការទីផ្សារ ធ្វើឲ្យគាត់មានជម្រើសច្រើនក្នុងការលក់ដូរ។

២. ម្ចាស់ម៉ាស៊ីនកិនស្រូវ : ដើម្បីឲ្យគាត់ ក) អាចប្រមូលទិញបានស្រូវច្រើន ប្រកបដោយគុណភាព ខ) អាចដំណើរការកិន និងផ្គត់ផ្គង់ដោយស្ថេរភាពប្រសិទ្ធភាព និងបានចំណេញច្រើន និង គ) យល់ដឹងអំពីតម្លៃ និងតម្រូវការទីផ្សារ ធ្វើឲ្យគាត់មានជម្រើសច្រើន។ ឃ) អ្នករកស៊ីទិញលក់ស្រូវអង្ករ : ដើម្បីឲ្យគាត់អាចប្រមូលទិញបានស្រូវច្រើន ប្រកបដោយគុណភាពខ្ពស់ ចាប់ពីដើមរហូតដល់ចុងឆ្នាំ ធ្វើឲ្យគាត់កើនសមត្ថភាពលក់នាំចេញ និងប្រាក់ចំណេញនិង ង) អ្នកបរិភោគ : ដើម្បីឲ្យគាត់មានស្បៀងច្រើន ប្រកបដោយគុណភាពខ្ពស់ធ្វើឲ្យគាត់អាចចំណាយតិច និងមានសុខភាពល្អ។